# I- ពិធីស្តីការគណៈរដ្ឋមន្ត្រី

## ១- អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៩៤

### អនុក្រឹត្យលេខ ១៦ អនក្រ

ស្តីពីការបង្កើតគណៈប្រតិភូចំរុះរៀបចំរដ្ឋបាល តំបន់ប៉ៃលិន

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័នព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់

**សំរេច**

**មាត្រា ១** : បង្កើតគណៈប្រតិភូចំរុះមួយដើម្បីរៀបចំរដ្ឋបាល តំបន់ប៉ៃលិន ដែលមានសមាសភាពដូចតទៅ ÷

១- ឯកឧត្តម **អ៊ឹម ឈុនលឹម** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សហប្រធាន

២- ឯកឧត្តម **ខាន សាវឿន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សហប្រធាន

៣- ឯកឧត្តម ឧត្តមសេនីយ៍ **ប៉ុល សារឿន** នាយករងអគ្គសេនាធិការកង យោធពលខេមរភូមិន្ទ អនុប្រធាន

៤- ឯកឧត្តម **ណាំ ជុំ** អភិបាលរងទី២ ខេត្តបាត់ដំបង អនុប្រធានប្រចាំការ

៥- ឯកឧត្តម ឧត្តមសេនីយ៍ **ហ៊ិល សារ័ន្ត** មេបញ្ជាការយោធភូមិភាគទី ៥ សមាជិក

៦- ឯកឧត្តម ឧត្តមសេនីយ៍ **ហ៊ាន ហ៊ុម** មេបញ្ជាការតំបន់ប្រតិបត្តិការខេត្តបាត់ដំបង សមាជិក

៧- ឯកឧត្តម **ត្រាំ អ៊ីវតឹក** អនុរដ្ឋលេខាធិការក្រសួងសាធារណការដឹកជញ្ជូន សមាជិក

៨- ឯកឧត្តម **ម៉ម ប៊ុនហេង** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

៩- ឯកឧត្តម **នាយ ចាន់** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១០- ឯកឧត្តម **អង្គបត្យេ ចន្ទ្រលាវ** ទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សមាជិក

១១- ឯកឧត្តម **ឃ្លោក ប៊ុនឌី** ទីប្រឹក្សាឯកឧត្តមយូ ហុកគ្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សមាជិក

១២-ឯកឧត្តម **សេង រ៉ុន** ទីប្រឹក្សាច្បាប់ ទីស្តីការនាយករដ្ឋមន្ត្រី សមាជិក

១៣-លោក **យូ ស៊ុនឡុង** ជំនួយការផ្ទាល់សម្តេចនាយករដ្ឋមន្ត្រីទី ២ សមាជិក

១៤-លោកឧត្តមសេនីយ៍ **ទ៉ានណយ** ស្នងការនគរបាលខេត្តបាត់ដំបង សមាជិក

១៥-លោក **ហួន សាខ៊ាង** ប្រធានស្តីទីនាយកដ្ឋានភូមិសាស្ត្រទីស្តីការ គណៈរដ្ឋមន្ត្រី សមាជិក

១៦-លោកឧត្តមសេនីយ៍**ប៉ែនអ៊ាន** ប្រធាននាយកដ្ឋាននគរបាលព្រំដែន ក្រសួងមហាផ្ទៃ សមាជិក

១៧-លោក **ប្រាជ្ញ ច័ន្ទ** ប្រធាននាយកដ្ឋានបាត់ទាំងរដ្ឋអំណាច ក្រសួងមហាផ្ទៃ សមាជិក

១៨-លោក **គុំ ឌិ** ជំនួយការរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ សមាជិក

១៩-លោក **លឹម ទ៉ាន់** អនុប្រធាននាយកដ្ឋានសុរិយោដីក្រសួងកសិកម្ម សមាជិក

២០-លោក **មេង គឹមលី** ជំនួយការរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ សមាជិក

២១-លោក **រាជ សុ ភ័ង** ប្រធានការិយាល័យបុគ្គលិក ក្រសួងមហាផ្ទៃ សមាជិក

**មាត្រា២** : គណៈប្រតិភូចំរុះនេះមានភារកិច្ចដូចតទៅ ÷

-លើកសំណើកំណត់ព្រំប្រទល់រដ្ឋបាល និង រៀបចំទំរង់បែបបទ បង្កើតក្រុងប៉ៃ លិន ។

-លើកសំណើរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ដែនដី ក្រុងប៉ៃ លិន ។

-ពិនិត្យលក្ខណសម្បត្តិជាក់ស្តែង លើកសំណើបង្កើតរដ្ឋបាលជំនាញឯទៀត ។

-រួមសហការជាមួយកងយោធពលខេមរភូមិន្ទ ដើម្បីទាក់ទងនិងដោះស្រាយបញ្ហានានា ដែលកើតមាននៅក្នុងក្រុង ។

-បំពេញការងារផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់អោយ ។

**មាត្រា ៣** :គណៈប្រតិភូចំរុះនេះ មានសិទ្ធិបង្កើតក្រុមជំនាញផ្សេង ៗ ជាជំនួយការ ។

**មាត្រា ៤** :សមាជិកទាំងអស់នៃគណៈប្រតិភូចំរុះនេះ ត្រូវចូលរួមធ្វើការងារ និង ប្រជុំតាមការអញ្ជើញ របស់ សហប្រធាន ។

**មាត្រា ៥** :គណៈប្រតិភូចំរុះនេះមានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៦** :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ និង ឯកឧត្តមអស់លោក ដែលមានឈ្មោះក្នុងមាត្រា ១ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

## II- ការងារបណ្តាក្រសួង

## ទីស្តីការក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ

## ប្រកាស

ភ្នំពេញ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ០៣៦ ប្រក សហវ**

**ស្តីពីការធ្វើនិយ័តភាពឥណទានផ្ទេរក្នុងជំពូកទី ១១**

**របស់ មន្ទីរឃោសនាការពត៌មាន រាជធានីភ្នំពេញ**